**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..០៧...សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១**

## I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាល ទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២) *ដំណាក់កាល ទី ២:* ការរៀបចំកញ្ចប់ថវិកាពីខែ មិថុនា ដល់ខែកញ្ញា និង*ដំណាក់កាលទី ៣:* ការអនុម័តថវិកា ពីខែតុលា ដល់ខែធ្នូ ។ ដើម្បីធានាការអនុវត្តច្បាប់នេះ និងដើម្បីបង្កើនការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ ***សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*** នៅដើមខែ មេសា សម្រាប់ដំណាក់កាលទី ១ និង ***សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ*** នៅដើមខែមិថុនា សម្រាប់ដំណាក់កាលទី ២ ។ ដូច្នេះ សារាចរនេះ គឺជាមគ្គុទ្ទេសក៍ សម្រាប់ណែនាំ និងធ្វើជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១-២០១៣ ដល់គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញគ្រប់រាជធានី ខេត្តទាំងអស់ ។

២- ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ជាពិសេស ដើម្បីបង្កើនការវិភាជន៍ថវិកា ឱ្យចំទិសដៅ និងបម្រើឱ្យសកម្មភាពអាទិភាពជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងគោលដៅសម្រេចឱ្យបាន នូវគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួង-ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រជាអាទិភាពរបស់វិស័យនីមួយៗ សម្រាប់រួមចំណែកសម្រេចឱ្យបាននូវគោលនយោបាយរួម របស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** តម្រូវឱ្យ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្តនីមួយៗ រៀបចំ និង ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** ជារៀងរាល់ឆ្នាំ ។ ផែនការយុទ្ធសាស្ត្រថវិកានេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣) ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី និង យុទ្ធសាស្ត្រអាទិភាព និង ពិសេស (៥) គឺជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាព ក្នុងការកំណត់កញ្ចប់ និង វិភាជន៍ថវិកា ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ បាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជន៍ និងការគ្រប់គ្រងថវិកា ជាពិសេសសម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ឱ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ ។ ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ អាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ តម្រូវឱ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង បញ្ចូលទាំងថវិកាចរន្ត និងថវិកាមូលធន រួមទាំងថវិកាជាតិ និងថវិកាដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវប្រើប្រាស់ក្រុមការងារថវិការបស់ក្រសួង-ស្ថាប័ន ដែលមានសមាសភាពមកពី នាយកដ្ឋានហិរញ្ញវត្ថុ ឬ/និងគណនេយ្យ នាយកដ្ឋានផែនការ និងអង្គភាពគ្រប់គ្រងគម្រោង ។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ ក្រសួង-ស្ថាប័ន និងវិស័យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពិនិត្យសម្រេច និង ចុះហត្ថលេខា ។ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ឱ្យបាន ***ត្រឹមថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០*** ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និង អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មកពិគ្រោះ និង សាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់ ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិវិភាជន៍កញ្ចប់ថវិកា ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### ក. *ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៤- បន្ទាប់ពីមានកំណើនខ្ពស់រយៈពេលមួយទសវត្សរ៍ និងកាត់បន្ថយបាននូវអត្រាភាពក្រីក្រគួរឱ្យកត់សម្គាល់មក សេដ្ឋកិច្ចកម្ពុជាត្រូវទទួលរងនូវផលប៉ះពាល់នៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងវិនភាពសេដ្ឋកិច្ចសកលលោក ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងលើវិស័យសេដ្ឋកិច្ចរបវន្ត និងរចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលទើបចាប់ផ្តើមវិវត្តផ្លាស់ប្តូរទៅរកដំណាក់កាលនៃការអភិវឌ្ឍមួយខ្ពស់ជាងមុន តាមរយៈការឆ្លុះបញ្ចាំងពីកំណើនឡើងជាលំដាប់ នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម ធៀបនឹងកសិកម្មនៅក្នុងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប(ផសស) ។ ប្រការនេះ បានធ្វើឱ្យការរួមចំណែកនៃវិស័យឧស្សាហកម្មធ្លាក់ចុះមកនៅត្រឹមប្រមាណ ២២% ក្នុងឆ្នាំ ២០០៨-២០០៩ បន្ទាប់ពីបានឡើងដល់ប្រមាណជាង ២៥% ក្នុងឆ្នាំ ២០០៦-២០០៧ ហើយវិស័យកសិកម្មបាន ឡើងដល់ប្រមាណជាង ៣៣% វិញ បន្ទាប់ពីធ្លាក់ចុះមកនៅត្រឹមប្រមាណ ៣០% ក្នុងឆ្នាំ ២០០៦-២០០៧ ក្នុងពេលដែលវិស័យសេវាកម្មរក្សាបានក្នុងកម្រិតប្រមាណជិត ៤០% ។ ដូច្នេះ វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទមិនត្រឹមតែនៅជាមូលដ្ឋានសំខាន់ និងចាំបាច់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាប៉ុណ្ណោះទេ ថែមទាំងជាមូលដ្ឋានចាំបាច់ និងមិនអាចខ្វះបានសម្រាប់ការពង្រីកមូលដ្ឋានសេដ្ឋកិច្ច ព្រមទាំងអាចជួយសង្គ្រោះ និងសម្រាលឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចប្រកបដោយភាពស័ក្តិសិទ្ធិថែម

ទៀតផង ។ ប្រការនេះ កាន់តែបញ្ជាក់ឱ្យឃើញថា ការបង្កើនទិន្នផល និង ផលិតភាពកសិកម្ម ការធ្វើពិពិធភាវូបនីយកម្មមូលដ្ឋាននៃកំណើនវិស័យកសិកម្ម និងការជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ព្រមទាំងសហគ្រាសធុនតូច និងមធ្យម នៅតែជាយុទ្ធសាស្ត្រដ៏សំខាន់ និងចាំបាច់ ដើម្បីបង្កើនតម្លៃបន្ថែមលើផលិតផលកសិកម្ម និងស្រូបយកពលកម្មដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម និងដើម្បីពង្រីកមូលដ្ឋានកំណើន រក្សាចីរភាព និងសមធម៌នៃកំណើនសេដ្ឋកិច្ច ក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពិសេសនៅជនបទស្របតាមគោលនយោបាយ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។

៥- ពិតណាស់ កម្ពុជាបានឆ្លើយតបទៅនឹងវិបត្តិយ៉ាងសកម្មតាមរយៈការធ្វើអន្តរាគមន៍របស់ហិរញ្ញវត្ថុសាធារណៈក្នុងកម្រិតមធ្យមក្នុងទិសដៅរក្សាស្ថិរភាពរូបិយវត្ថុ និងគាំទ្រចីរភាពកំណើនសេដ្ឋកិច្ច។ នេះគឺដោយសារសេដ្ឋកិច្ចកម្ពុជាមានទំហំតូច និងបើកចំហ ព្រមទាំងមានសេរីភាវូបនីយកម្មគណនីចរន្ត ដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាចំណុះស្ទើរតែទាំងស្រុងទៅលើចីរភាពនៃការពង្រីកពាណិជ្ជកម្មអន្តរជាតិ និងលំហូរចូលនៃមូលធនបរទេស ។ ទោះជាយ៉ាងណា ការចាប់ផ្តើមងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយពីវិបត្តិដ៏ធ្ងន់ធ្ងរនេះនឹងត្រូវការពេលវេលាមួយសមស្រប ដើម្បីស្តារស្ថានភាពមករកភាពប្រក្រតី ទើងន និងប្រាកដប្រជាឡើងវិញ ។ ម្យ៉ាងទៀត យើងក៏កំពុងប្រឈមមុខនឹងបញ្ហាដ៏ស្រួចស្រាល់មួយ គឺការបោះទីតាំងលើទីផ្សារថ្មីៗបន្ថែមលើទីផ្សារអាមេរិក និងអឺរ៉ុប ព្រមទាំងការប្រជែងយកប្រភពហិរញ្ញវត្ថុទាំងក្នុងទម្រង់ជាហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ និងការវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងពីប្រភពផ្សេងៗទៀត ដើម្បីធ្វើហិរញ្ញប្បទានដល់កំណើន និងការអភិវឌ្ឍរបស់យើង ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងត្រូវបន្តតាមដានឱ្យបាន និងគ្រប់គ្រងឱ្យបាននូវសភាពការណ៍ក្នុងប្រទេស តំបន់ និងសកលលោក ដូចដែលរាជរដ្ឋាភិបាលធ្លាប់បានអនុវត្តប្រកបដោយប្រសិទ្ធភាពកន្លងមក តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្ត និងបន្តដាក់ចេញនូវគោលនយោបាយជាប្រព័ន្ធ ស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា សំដៅធានាស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងធានាបាននូវភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុ គ្រប់គ្រងបាននូវអតិផរណា បង្កើតបាននូវបរិស្ថានកាន់តែអនុគ្រោះ សម្រាប់សកម្មភាពសេដ្ឋកិច្ច និងធុរកិច្ច ព្រមទាំងពង្រឹងបាននូវប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ ។ ទន្ទឹមនឹងនេះ ដោយវិស័យឧស្សាហកម្ម និងសេវាកម្ម គឺជាវិស័យដែលងាយរងគ្រោះ ដោយសារកត្តាពីខាងក្រៅ ពិសេសលើការនាំចេញសំលៀកបំពាក់ ទេសចរណ៍ ទីផ្សារអចលនទ្រព្យ និងសំណង់ រាជរដ្ឋាភិបាលនឹងត្រូវបន្តពង្រឹងការបោះទីតាំងលើទីផ្សារថ្មី បន្តជំរុញការវិនិយោគក្នុងស្រុក បន្តពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារ និងបន្តកែលម្អសេវាទេសចរណ៍ ដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានពីខាងក្រៅផង ព្រមទាំងដើម្បីបង្កើនភាពធនវត្តភាព និងពង្រីកសក្តានុពលភាពនៃវិស័យទាំងពីរនេះផង ។

៦- ឆ្នាំ ២០០៩ កន្លងទៅនេះ តាមការគណនាជាបណ្តោះអាសន្នរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានប្រមាណ ០,១% ធៀបនឹងការព្យាករណ៍ ២,១% នៅចុងឆ្នាំ ក្នុងពេលរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០។ ប្រការនេះ គឺដោយសារការរងឥទ្ធិពលអវិជ្ជមានពីខាងក្រៅ

តាំងពីចុង ឆ្នាំ ២០០៨ រហូតមក ដូចជាកត្តាអតិផរណាខ្ពស់ ការធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងវិនភាពសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលឱ្យកំណើនសេដ្ឋកិច្ចស្ទើរតែគ្រប់ប្រទេសមានការធ្លាក់ចុះរហូតដល់ក្រោមសូន្យ ។ សម្រាប់កម្ពុជា លទ្ធផលនៃកំណើនវិជ្ជមាននេះបានមកដោយសារវិស័យកសិកម្មនៅតែរក្សាបាននូវកំណើន ៥,៤% ធៀបនឹង កំណើន ៥,៧% ក្នុងឆ្នាំ ២០០៨ វិស័យសេវាកម្មរក្សាបានកំណើនត្រឹម ២,៣% ធៀបនឹងកំណើន ៩% ក្នុងឆ្នាំ ២០០៨ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍បានកើនឡើងប្រមាណ ២,៩% ធៀបនឹង ១០% នៅក្នុងឆ្នាំ ២០០៨) រីឯវិស័យឧស្សាហកម្មបានថយចុះ ៩,៥% ធៀបនឹងកំណើន ៤% ក្នុងឆ្នាំ ២០០៨ (ក្នុងនោះផលិតផលវាយនភ័ណ្ឌ បានថយចុះ ៩% ធៀបនឹងកំណើន ២,២% ក្នុងឆ្នាំ ២០០៨ និងផលិតផលសំណង់បានកើនឡើង ៥% ធៀបនឹង ៥,៤% ក្នុងឆ្នាំ ២០០៨) ។

៧- តាមការព្យាករណ៍ដោយមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០១០ នេះ អាចនឹងសម្រេចបានក្នុងរង្វង់ជុំវិញ ៥% ធៀបទៅនឹងការព្យាករណ៍ ៣% នៅក្នុងការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០ ។ វិស័យកសិកម្មនឹងនៅតែមានកំណើនប្រមាណ ៤% វិស័យឧស្សាហកម្មនឹងមានកំណើន ប្រមាណ ១០,៥% ពិសេសដោយសារផលិតផលវាយនភ័ណ្ឌ ដែលនឹងត្រឡប់មកមានកំណើនប្រមាណ ២,២% វិញ ផលិតផលសំណង់នឹងនៅបន្តរក្សាបាន នូវកំណើនប្រមាណ ៣,៥% និង វិស័យសេវាកម្មនឹងបន្តមានកំណើនប្រមាណ ៣,៣% ដោយសារអាជីវកម្មទេសចរណ៍អាចនឹងមានកំណើនប្រមាណ ៣,៣% ។ ស្ថានភាពសេដ្ឋកិច្ចបាន និងកំពុងងើបឡើងវិញដោយសន្សឹមៗ ចាប់តាំងពីចុងឆ្នាំ ២០០៩ មក ពិសេសលើវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលជាវិស័យនៅមានលក្ខណៈផុយស្រួយ និងមានមូលដ្ឋានតូចចង្អៀត ព្រមទាំងនៅពឹងផ្អែកខ្លាំងលើទីផ្សារខាងក្រៅ ។ ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅមានភាពមិនប្រាកដប្រជាខ្ពស់នៅឡើយ ដែលធ្វើឱ្យការព្យាករណ៍លើសូចនាករម៉ាក្រូសេដ្ឋកិច្ច នៅមានការលំបាក និងមានសុក្រឹតភាពទាបនៅឡើយ ។ ដូច្នេះ ការតាមដានត្រួតពិនិត្យជាប្រចាំ និងការត្រៀមលក្ខណៈចាត់វិធានការបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពគឺជាប្រការសំខាន់ ។ ទោះជាយ៉ាងណា ការព្យាករណ៍សូចនាករម៉ាក្រូសេដ្ឋកិច្ច គឺមានភាពចាំបាច់សម្រាប់ការគ្រោងថវិកា និងតម្រង់ទិសចំណូល-ចំណាយ ។ ដូច្នេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបន្តការអង្កេត និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចជាប្រចាំ ដើម្បីឱ្យការព្យាករណ៍ប្រកបដោយបច្ចុប្បន្នភាព និងអាចជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាពសម្រាប់ការគ្រោងថវិកា និងតម្រង់ទិស ចំណូល-ចំណាយ ព្រមទាំងជាមូលដ្ឋានដ៏ស័ក្តិសិទ្ធិសម្រាប់ការលើកអនុសាសន៍ និងវិធានការឱ្យបានទាន់ពេលវេលា ។

៨- ក្នុងឆ្នាំ ២០០៩ កន្លងទៅនេះ អតិផរណាមធ្យមប្រចាំឆ្នាំបានធ្លាក់ចុះមកនៅត្រឹមប្រមាណ ៥,៣% បន្ទាប់ពីបានកើនឡើងរហូតដល់ ១៩,៧% នៅក្នុងឆ្នាំ ២០០៨ ។ តាមការព្យាករណ៍ អតិផរណាមធ្យមប្រចាំឆ្នាំ ២០១០ នេះ អាចនឹងកើនឡើងតិចតួចពីឆ្នាំ ២០០៩ គឺក្នុងរង្វង់ប្រមាណ ៦% ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ច និងនិន្នាការកើនឡើងនៃតម្លៃប្រេងឥន្ធនៈ លើទីផ្សារពិភពលោក ។ ដូច្នេះ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១ នៅក្នុងខែ មេសា និង ឧសភាខាងមុខនេះ កំណើនសេដ្ឋកិច្ចត្រូវបាន

ព្យាករណ៍ក្នុងរង្វង់ ៦% និង អត្រាអតិផរណាជា មធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៥% ។ អាស្រ័យដោយភាពវិវត្ត ជាក់ស្តែងនៃស្ថានភាពសេដ្ឋកិច្ចនៅក្នុង ដំណាក់កាលនៃការរៀបចំគញប់ថវិកាឆ្នាំ ២០១១ ប្រសិនបើមានការ ផ្លាស់ប្តូរធំដុំ នោះនឹងត្រូវកែសម្រួលការព្យាករណ៍នេះនៅក្នុង**សារាចរណែនាំសម្រាប់ការរៀបចំសេចក្តីព្រាង ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១១** ដែលត្រូវដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សម្រេចនៅ ដើមខែ មិថុនា ឆ្នាំ ២០១០ ។

**ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

៩- ឆ្នាំ ២០១០ នេះ តាមការព្យាករណ៍ប្រកបដោយការប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចអាចនឹងសម្រេច បានប្រមាណ ៥% ខ្ពស់ជាងការព្យាករណ៍នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ (៣%) ដូច្នេះ យើងសង្ឃឹមថាស្ថានភាពហិរញ្ញវត្ថុសាធារណៈ គួរតែមានលក្ខណៈប្រសើរជាងការគ្រោងនៅក្នុងច្បាប់ ពិសេសលើការអនុវត្តចំណូល- ចំណាយនៃថវិកា ។ ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាធារណៈ ប្រកបដោយភាពត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការជំរុញការកែលម្អ និងការ ពង្រឹងការប្រមូល និងគ្រប់គ្រងចំណូល និងការកែលម្អ និងពង្រឹងការអនុវត្ត និងការគ្រប់គ្រងចំណាយ ពិសេសក្នុងក្រមខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នោះនឹងអាចធ្វើឱ្យការអនុវត្តថវិកា ឆ្នាំ ២០១០ សម្រេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុ ។ តាមការព្យាករណ៍ ចំណូលក្នុងស្រុកសរុបនឹង អាចកើនឡើងប្រមាណ ១៦,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ គឺនឹងសម្រេចបានប្រមាណ ១២,៥៦% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសម្រេចបាន ១០,៦១% នៃផសស (ក្នុងនោះ ចំណូលគយ និងរដ្ឋាករស្មើនឹង ៥,៤៨% និងចំណូលពន្ធដារស្មើនឹង ៤,៣៨%) ចំណូល មិនមែនសារពើពន្ធនឹងសម្រេច បាន ១,៨៤% នៃផសស ។ ចំណាយសរុបអាចនឹងកើនដល់ ១៧,៩៥% នៃផសស គឺកើនឡើងប្រមាណ ០,៨៩% នៃផសស ធៀបនឹងឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណាយចរន្ត នឹងកើនដល់ប្រមាណ ១០,៨៩% នៃផសស គឺកើនឡើងប្រមាណ ០,៧៧% នៃផសស ធៀបនឹងឆ្នាំ ២០០៩ និង ចំណាយមូលធនអាចនឹងកើន ឡើងដល់ប្រមាណ ៧,០៦% នៃផសស គឺកើនឡើង ប្រមាណ ០,១% នៃផសស ធៀប នឹងឆ្នាំ ២០០៩ ។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើឱ្យមានអតិរេកចរន្តប្រមាណ ១,៥៦% និង ឱនភាពថវិកាសរុប ប្រមាណ ៥,៤០% នៃផសស ។

១០- ដោយឈរលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី ២** របស់រាជរដ្ឋាភិបាល គួបផ្សំនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាធារណៈ ថវិកាឆ្នាំ ២០១១ មានគោលដៅសំខាន់ៗ ដូចតទៅ :

- ធានាការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស ការបន្តជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** *ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព* សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ ២០១១-២០១៣ ។

- ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដូចជាៈ
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកំពស់សេវាសាធារណៈនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល និងសុវត្ថិភាពសង្គម ។
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកំពស់សកម្មភាពដែលបម្រើឱ្យវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍជនបទ ។
- ធានាការបន្តអនុវត្តកម្មវិធីកែទម្រង់ និង កម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ កម្មវិធីកែទម្រង់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ កម្មវិធីកែទម្រង់កងទ័ព កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កម្មវិធីអភិវឌ្ឍន៍ផ្នែកឯកជន និងការពង្រឹងអភិបាលកិច្ចល្អ របស់រាជរដ្ឋាភិបាល ។

១១- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើនេះ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០១១ ត្រូវគ្រោង និងរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ៖

- បន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការប្រមូលចំណូល ជាពិសេសការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃយុទ្ធនាការនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឱ្យបាននូវកម្រិតចំណូលក្នុងស្រុកសរុប ប្រមាណ ១២,៧៣% នៃផសស គឺមាន កំណើន ០,១៦% នៃផសស ធៀបនឹងឆ្នាំ ២០១០ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសម្រេចឱ្យបាន ១១,០៥% នៃផសស គឺមានកំណើន ០,៤៣% នៃផសស ធៀបនឹងឆ្នាំ ២០១០ ចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន ១,៥៨% នៃផសស គឺថយចុះ ០,២៦% នៃផសស ធៀបនឹងឆ្នាំ ២០១០ ។
- បន្តពង្រឹងការរៀបចំថវិកាឱ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រឹតភាព តាមរយៈការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឱ្យបានច្បាស់លាស់ និងសុក្រឹត ការធ្វើសមាហរណកម្មថវិកា និងការបន្តកែលម្អការអនុវត្តថវិកាកម្មវិធី ។
- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំការបន្តពង្រឹងការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ និង ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** ដែលសម្រេចបាននៅក្នុងជំហានទី ១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់

និងចាំបាច់ សម្រាប់ជាមូលដ្ឋាននៃការកសាងជំហានទី ២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និង បណ្តាជំហានបន្តបន្ទាប់ទៀត ។

- បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និង ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ ឱ្យកាន់តែសុក្រឹត ព្រមទាំងការត្រួតពិនិត្យផ្ទៃក្នុង និង ជាពិសេស ឈានទៅកំណត់ និងដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបថ និងនីតិវិធី អនុវត្ត ថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលជាសកម្មភាពការងារដំបូង សម្រាប់សម្រេចជំហានទី ២ គឺ ***ការបង្កើន ប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយ អគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបឱ្យស្ថិតនៅក្នុងកម្រិត ១៨,១០% នៃផសស គឺកើនឡើងប្រមាណ ០,១៨% នៃផសស ដែលក្នុងនោះ ចំណាយចរន្តនឹងត្រូវបានរក្សាឱ្យនៅត្រឹមប្រមាណ ១០,៩៥% និងចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៧,១៥% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៦៨% នៃផសស និង និនភាពថវិកាសរុបក្នុងរង្វង់ ៥,៣៧% នៃផសស ។
- បន្តផ្តល់អាទិភាព និង ជំរុញការអនុវត្តថវិកាតាមកម្មវិធី និង ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស បន្តពិនិត្យលទ្ធភាពដើម្បីពង្រីកការសាកល្បង ការអនុវត្តថវិកាតាមកម្មវិធី តាមរយៈការបង្កើនទំហំថវិកាតាមកម្មវិធី និង ពង្រីកការអនុវត្តទៅក្រសួងផ្សេងទៀតក្រៅពីក្រសួង ៨ ដែលបាន និងកំពុង អនុវត្តនៅក្នុង ឆ្នាំ ២០០៩ នេះ (ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ។
- បន្តផ្តល់អាទិភាពលើកិច្ចការវិនិយោគសាធារណៈ ជាពិសេស លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវ ស្ពាន ប្រព័ន្ធស្រោចស្រព និង ការវិនិយោគលើការលើកកំពស់ផលិតភាព កសិកម្ម ។

## III. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១២- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១០-២០១២ របស់ខ្លួន និង ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តកន្លងមក ដើម្បីកែសម្រួល និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១-២០១៣ ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។ គំរូផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០១១-២០១៣ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នេះរួមមាន ៦ ផ្នែកគឺៈ

***ផ្នែកទី ១: សេចក្តីផ្តើម*** គឺជាការរៀបរាប់អំពីមុខងារ និងភារកិច្ចរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អំពីស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាក្នុងឆ្នាំកន្លងមក និងឆ្នាំកំពុងអនុវត្ត និងអំពី

ការចូលរួមចំណែកក្នុងការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដើម្បីសម្រេចបាននូវគោលនយោបាយរួម របស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ។

***ផ្នែកទី ២: គោលបំណងគោលនយោបាយ*** គឺជាគោលបំណងគោលនយោបាយរយៈពេលមធ្យម (ពី ៣ ទៅ ៥ ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង-ស្ថាប័ន ហើយដែលត្រូវបានរៀបចំនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដែលជាយុទ្ធសាស្ត្រគោលនយោបាយដើម្បីអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់កម្រិតជីវភាព របស់ប្រជាពលរដ្ឋ ។

***ផ្នែកទី ៣: កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព*** គឺជាកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២ ខាងលើ ។ ការកំណត់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺរួមមានទាំង កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពសម្រាប់ថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដូចក្នុងតារាងទី ៣.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

***ផ្នែកទី ៤: ការកំណត់សូចនាករ និងគោលដៅសូចនាករ*** គឺជាការកំណត់សូចនាករ និង គោលដៅសូចនាកររបស់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ សម្រាប់តាមដាន និងវាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ ដែលបានរៀបចំដើម្បីសម្រេចបាននូវគោលដៅនៃគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលបានកំណត់ ។ សូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និងកំណត់គោលដៅនៃលទ្ធផលចុងក្រោយ ដូចក្នុងតារាងទី ៤.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៥: ការកំណត់ធនធាន*** គឺជាការគ្រោងតម្រូវការចំណាយ និង ចំណូលសម្រាប់រយៈពេល ៣ ឆ្នាំ (២០១១-២០១៣) ហើយការគ្រោងនេះ គឺត្រូវគិតបញ្ចូលទាំងថវិកាជាតិ និង ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។ ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ (២០១១-២០១៣) ទៅតាមកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និង ប្រភពធនធានរួមទាំងថវិកាជាតិ និង ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដូចក្នុងតារាងទី ៥.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយ នឹងសារាចរណែនាំនេះ ។ ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល ៣ ឆ្នាំ (២០១១-២០១៣) ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និង បទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និង វិធានការថ្មីដែលគ្រោងនឹងដាក់ឱ្យអនុវត្ត ។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទនៃចំណូលទាំងអស់រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និង ប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និង ចំណូលដែលបានមកពីដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួង-ស្ថាប័ន ដូចក្នុងតារាងទី ៥.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយ នឹងសារាចរណែនាំនេះ។

*ផ្នែកទី ៦: សេចក្តីសន្និដ្ឋាន* គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១ និង ការបើកទិសដៅ ក៏ដូចជាវិធានការ ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១ ។

១៣- ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណី ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"*ដើម្បីជូនជ្រាប*"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
"*ដើម្បីអនុវត្ត*"
-ឯកសារ-កាលប្បវត្តិ